# U

Unisexual: **មានភេទតែមួយ ផ្កាដែលមានតែកេសរញី ឬមានតែកេសរឈ្មោល**

ន័យដូចពាក្យ Imperfect flower (ផ្កាមិនពេញលេញ)។

មើល Hermaphrodite.

Upgrading: **ការបង្កើនគុណភាព**

ការធ្វើឱ្យប្រសើរឡើងនូវគុណភាពមធ្យម ឬការសំដែងឡើង ដោយធ្វើការបំបាត់ឯកត្តៈអន់។ ន័យទាក់ទងនឹងគ្រាប់ពូជ គឺជាការបង្កើនលទ្ធភាពរស់ និងសុខភាពរឹងមាំរបស់កញ្ចប់គ្រាប់ ដោយការសរិតសំរាំងចេញនូវគ្រាប់តូចៗ មិនទុំ ស្អៀត និងម្យ៉ាងទៀត គ្រាប់ពូជអន់ចេញពីកញ្ចប់គ្រាប់ពូជ។ ន័យទាក់ទង និងប្រភពផលិតគ្រាប់ពូជ គឺកាប់ចេញនូវដើមដែលមានហ្វីណូថៃបអន់ ដើម្បីបង្កើនគុណភាពជីននេទិក ឧ:ការបង្កើតតំបន់ផលិតគ្រាប់ពូជ។

មើល Grading.